*(Unofficial Translation)*

**Kingdom of Cambodia**

**Royal Government of Cambodia** **Nation Religion King**

**No. 57 ANK-BK**

# Sub-Decree
# On
# Administrative Measures for Preventing the Spread of COVID-19 and other Severe and Dangerous Contagious Diseases

## Royal Government

- Having seen the Constitution of the Kingdom of Cambodia;
- Having seen Royal Decree No. NS/RKT/0918/925, dated 06 September 2018, on the appointment of the Royal Government of the Kingdom of Cambodia;
- Having seen Royal Decree No. NS/RKT/0320/421, dated 30 March 2020, on the appointment and reshuffle of the Royal Government members, the Kingdom of Cambodia;
- Having seen Royal Kram No. NS/RKM/0618/012, dated 28 June 2018, promulgating the Law on the Organization and Functioning of the Council of Ministers;
- Having seen Royal Kram No. NS/RKM/0321/004, dated 11 March 2021, promulgating the Law on Preventive Measures against the Spread of COVID-19 and other Severe and Dangerous Contagious Diseases;
- Having seen Sub-Decree No.37 ANK-BK, dated 12 March 2021, on Health Measures for Preventing the Spread of COVID-19 and other Severe and Dangerous Contagious Diseases;
- Based on the necessity of Combatting and Preventing the Spread of COVID-19

## Hereby decided

## CHAPTER I

## General Provisions

**Article 1- Purpose**

This Sub-Decree sets out administrative measures in accordance with the Law on Preventive Measures against the Spread of COVID-19 and other Severe and Dangerous Contagious Diseases and to be aimed at protecting the lives of people, public health and order as well as at minimizing to the maximum impacts of the diseases on socio-economic sectors in the Kingdom of Cambodia.

**Article 2- Scope**

This Sub-Decree shall apply to the prevention of the spread of COVID-19 and other severe and dangerous contagious diseases as determined by the Ministry of Health in the Kingdom of Cambodia.

## CHAPTER II

## Administrative Measures

### Part I

### Types of Administrative Measures

**Article 3- Administrative Measures**

In order to combat and prevent the spread of COVID-19 in the Kingdom of Cambodia, necessary administrative measures to be taken include:

- Restriction or prohibition of travels;
- Restriction or prohibition of meeting and gathering of people which may cause the spread of COVID-19;
- Prohibition or restriction on business operations or professional activities that are risky or the sources of the spread of COVID-19;
- Restriction or travel bans to COVID-19 affected areas or places;
- Curfew;
- Lockdown of certain COVID-19 infected areas or places;
- Restriction or prohibition of trade of goods that are risky or the sources of the spread of COVID-19; and
- Other administrative measures necessary for responding to and preventing the spread of COVID-19

### Part II

### Meaning of Administrative Measures

**Article 4- Restriction or Prohibition of Travels**

Travels from home or current residence may be restricted or prohibited except for the following necessary circumstances:

- Travels to work or professional or business activities that are not restricted or prohibited and with workplace, professional or business certificate.
- Travels to buy groceries and other basic necessities;
- Travels to hospital, health centres, maternity, treatment facility or pharmacies due to urgent health reasons;
- Travels to present oneself before health officials for sample collection and COVID-19 testing and for scheduled COVID-19 vaccination;
- Individual sporting activities within their commune-sangkat residential area that do not involve a gathering;
- Travels to fulfil a legal obligation and present oneself before a judicial police or court;
- Travels to join an activity in public interests or other necessary purposes as per a request or requirement by a public authority; and
- Travels for urgent and necessary reasons, such as in case of a family member in severe and emergency condition or death of a family member.

**Article 5- Restriction or prohibition of meeting or gathering of people**

Any meeting or gathering of people may be restricted or prohibited except for necessary circumstances as the following:

- A gathering of family members living in the same household or residence;
- A funeral organized in accordance with the regulations of a competent authority;
- A gathering to implement health measures, such as for sample collection for COVID-19 testing and for COVID-19 vaccination;
- A gathering to provide necessary support for vulnerable people or victims;
- A gathering of people during a proceeding by a judicial police or court;
- A necessary gathering in public interests or other purposes as per the requirement of a competent authority

**Article 6- Prohibition or restriction on business operations or professional activities**

Every work, business operation or professional activity may be temporarily suspended except for the following circumstances:

- Civil servants work or work relating to provision of public service required by each institution, namely electricity supply, water supply, rubbish fee collection;
- Every online work, business operation or professional activity;
- Emergency, health and pharmacy service;
- Supply of staple goods or service, namely groceries, petroleum stations, post and telecommunication services;
- Restaurants and eateries selling takeaway;
- Goods delivery services; and
- Other work, business operation and professional activities permitted by a competent authority

**Article 7- Restriction or travel bans**

Travels to a COVID-19 affected area or place may be restricted or prohibited except for emergency, urgent necessary public services or goods delivery services.

**Article 8- Curfew**

Any travel allowed in Article 4 of this Sub-Decree shall not be allowed between 20:00 pm to 05:00 am except for a travel for health emergency and family reasons, goods delivery, fulfillment of obligation in public interests, travels to undertake enterprise, establishment or business operation as exempted and stipulated in the following Paragraph and other necessary circumstances permitted by a competent authority.

Every public enterprise, private enterprise or establishment or business that is permitted to operate in accordance with Article 6 of this Sub-Decree shall suspend their operation and direct customer reception from 20:00 pm to 05:00 am except for emergency, health and pharmacy, petroleum services and other public services that are permitted by a competent authority.

**Article 9- Lockdown of certain COVID-19 infected areas or places**

Any travel to and from areas or places on lockdown may be prohibited except for travels to provide emergency and urgent and necessary public services or transportation of goods as well as other necessary circumstances permitted by a competent authority.

During lockdown, administrative measures stipulated in Articles 4,5,6,7,8 and 10 of this Sub-Decree shall be implemented in their entirety or in part.

During implementation f lockdown measures, every individual is obliged to wear a mask and keep a physical distance as well as sanitation and temperature screening in order to combat and prevent the spread of COVID-19.

**Article 10- Restriction or prohibition of trade of goods that risky or the sources of the spread of COVID-19**

Goods that are risky or the sources of the spread of COVID-19 determined by the Ministry of Health may be restricted or prohibited from being traded in any form in the market and supply in the Kingdom of Cambodia.

## CHAPTER III
## Authority to Introduce Administrative Measures

**Article 11- The authority to introduce administrative measures**

Imposition of a municipality or province on lockdown and other administrative measures with a scope of application beyond the municipality or province or with a nation-wide scope of application shall be determined the Royal Government.

Municipal-provincial boards of governors obtain a mandate to decide any administrative measures that are applicable to certain parts or places in their municipal-provincial territory or are applicable throughout the municipal-provincial territory where there is COVID-19 infection.

**Article 12- Conditions for Imposing Administrative Measures**

Any administrative measures under the scope of this Sub-Decree shall be imposed on a temporary basis for a period of not exceeding two weeks. The period may be extended or ended before the prescribed period under the same conditions when the administrative measures are imposed in accordance with Article 11 of this Sub-Decree.

**Article 13- Authority of the Board of Municipal-Provincial Governors**

Relevant municipal-provincial board of governors shall be responsible for effective implementation of measures imposed in accordance with Paragraph 1 of Article 11 of this Sub-Decree.

Relevant municipal-provincial board of governors have the authority to set up necessary mechanisms for controlling, monitoring and implementation of measures imposed in accordance with Article 11 of this Sub-Decree within its jurisdiction.

Relevant municipal-provincial board of governors may issue detailed guidance on implementation of administrative measures imposed in accordance with this Sub-Decree in order to ensure effective implementation within its jurisdiction.

Concerned municipal-provincial board of governors have the right to relax any administrative measures that they have introduced in accordance with Paragraph 2 of Article 11 of this Sub-Decree but shall respect all specific exceptions of each administrative measure as defined in this Sub-Decree.

In case of urgency and necessity, municipal-provincial board of governors have the right to impose other administrative measures aimed at ensuring effective control of the spread of COVID-19 in their jurisdiction and preventing the disease from spreading to other areas.

## CHAPTER IV
## Penalties

**Article 14- Punishments for Infringement of Administrative Measures**

Any individual who intentionally infringes any administrative measures as stipulated in Chapters II and III under this Sub-Decree shall be punishable under Article 10 of the Law on Preventive Measures against the Spread of COVID-19 and other Severe and Dangerous Contagious Diseases.

Imposition of transitional fines for infringement of administrative measures shall be under the authority of sub-national authorities. Detailed procedures for imposing transitional fines shall be determined by municipal-provincial board of governors.

Formats of fine slips and management of funds collected from transitional fines shall be determined by an inter-ministerial Prakas between the Ministry of Interior and Ministry of Economy and Finance.

**Article 15- Punishments for Obstruction of Administrative Measure Enforcement**

Any act of intentional obstruction or deterrence of the enforcement of administrative measures as stipulated in Chapters II and III of this Sub-Decree shall be punishable under Article 11 of the Law on Preventive Measures against the Spread of COVID-19 and other Severe and Dangerous Contagious Diseases.

**Article 16- Punishments for Infringement of Health Measures**

Any individual who shirks their responsibilities as stipulated in Paragraph 3 of Article 9 under this Sub-Decree shall be punishable under Articles 19 and 20 of the Sub-Decree on Health Measures for Preventing the Spread of COVID-19 and other Severe and Dangerous Contagious Diseases.

**Article 17- Liability of Competent Authorities**

Any competent official who arbitrarily uses their authority in contradiction to the purposes of this Sub-Decree and causes infringement of individual's rights and freedoms, physical integrity or causes damage to property of another person shall be liable for their act in accordance with the laws of the Kingdom of Cambodia.

**Article 18- Exemption or Mitigation of Criminal Liability**

Any offender of Articles 14 and 15 of this Sub-Decree may have their criminal liability exempted or mitigated if they provide relevant information to health or competent officials or necessary cooperation useful for the timely prevention of the spread of COVID-19.

The above exemption or mitigation of a criminal liability shall also be applicable in case where family members of the offender of Articles 14 and 15 of this Sub-Decree provide relevant information to health or competent officials or necessary cooperation useful for the timely prevention of the spread of COVID-19.

**Article 19- Application of other Criminal Laws**

Application of the provisions in Chapter IV of this Sub-Decree shall not prejudice the application of other criminal laws provided that an act defined as an offence in this Sub-Decree also constitutes an offence in other criminal laws.

*(Unofficial Translation)*

## CHAPTER V
## Same Application to other Severe and Dangerous Contagious Diseases

### Article 20- Same Application of all Provisions of this Sub-Decree to other Severe and Dangerous Contagious Diseases

All administrative measures and penalty provisions of this Sub-Decree applicable for COVID-19 shall apply *mutatis mutandis* to other severe and dangerous contagious diseases to be determined by the Ministry of Health under the scope of the Law on Preventive Measures against the Spread of COVID-19 and other Severe and Dangerous Contagious Diseases.

## CHAPTER VI
## Transitional Provision

### Article 21- Continuing Validity of Regulations Issued Prior to this Sub-Decree

All regulations concerning administrative measures aimed at combating and preventing the spread of COVID-19, issued prior to the entry in force of this Sub-Decree and which are not contrary to this Sub-Decree shall remain effective and enforceable until otherwise replaced by other newly issued regulations.

## CHAPTER VII
## Final Provisions

### Article 22- Abrogation

Any provision contrary to this Sub-Decree shall be abrogated.

### Article 23- Implementing Institutions

Minister in charge of the Council of Ministers, Minister of Economy and Finance, Minister of Interior, Minister of Health, Minister of Justice, and all ministers and heads of institutions shall implement this Sub-Decree in their capacity from the date of this signature onwards.

Phnom Penh, 31 March 2021

**Prime Minister**

Signature and Seal

***Samdech Akka Moha Sena Padei Techo* Hun Sen**

***(Unofficial Translation)***

**CC:**
- Ministry of Royal Palace
- General Secretariat of the Constitutional Council
- General Secretariat of the Senate
- General Secretariat of the National Assembly
- Cabinet of *Samdech Akka Moha Sena Padei Techo* Prime Minister
- Cabinet of *Samdech,* Her/His Excellency Deputy Prime Ministers
- As Stipulated in Article 23
- Royal Gazette
- Records – Archives

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៥៨៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## វិធានការរដ្ឋបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២១/០០៤ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- យោងតាមតម្រូវការចាំបាច់ក្នុងការប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .- គោលបំណង**

អនុក្រឹត្យនេះ កំណត់អំពីវិធានការរដ្ឋបាល ស្របតាមច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត សំដៅការពារអាយុជីវិតរបស់ប្រជាពលរដ្ឋ សុខភាពសាធារណៈ និងសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងកាត់បន្ថយឱ្យបានជាអតិបរមានូវផលប៉ះពាល់នៃការឆ្លងជំងឺនេះ ចំពោះវិស័យសង្គម និងសេដ្ឋកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## មាត្រា២ .. វិសាលភាព

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀតតាមការកំណត់របស់ក្រសួងសុខាភិបាល នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

# ជំពូកទី២
# វិធានការរដ្ឋបាលដែលត្រូវអនុវត្ត
## ផ្នែកទី១
## ប្រភេទនៃវិធានការរដ្ឋបាល

## មាត្រា៣ .. វិធានការរដ្ឋបាលនានា

ក្នុងគោលដៅប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងព្រះរាជាណាចក្រកម្ពុជា វិធានការរដ្ឋបាលចាំបាច់នានាដែលត្រូវអនុវត្ត មានជាអាទិ៍៖

- ការរឹតត្បិត ឬការហាមឃាត់ការធ្វើដំណើរ
- ការរឹតត្បិត ឬការហាមឃាត់ការជួបជុំនិងការប្រមូលផ្តុំមនុស្សដែលសកម្មភាពនេះអាចបណ្តាលឱ្យមានការឆ្លងរាលដាលនៃជំងឺកូវីដ-១៩
- ការហាមឃាត់ ឬការកម្រិតការធ្វើសកម្មភាពការងារឬមុខរបរដែលជាហានិភ័យឬជាប្រភពនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩
- ការរឹតត្បិត ឬហាមឃាត់ការធ្វើចរាចរណ៍ចេញ-ចូលតំបន់ ឬទីកន្លែងដែលមានការឆ្លងរាលដាលនៃជំងឺកូវីដ-១៩
- បម្រាមគោចរ
- ការបិទខ្ទប់តំបន់ ឬទីកន្លែងដែលមានការឆ្លងរាលដាលនៃជំងឺកូវីដ-១៩
- ការរឹតត្បិត ឬការហាមឃាត់ការធ្វើពាណិជ្ជកម្មលើទំនិញដែលជាហានិភ័យ ឬជាប្រភពនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និង
- វិធានការរដ្ឋបាលផ្សេងទៀតដែលមានភាពចាំបាច់ ដើម្បីឆ្លើយតបនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

## ផ្នែកទី២
## ខ្លឹមសារនៃវិធានការរដ្ឋបាល

## មាត្រា៤ .. ការរឹតត្បិត ឬការហាមឃាត់ការធ្វើដំណើរ

ការធ្វើដំណើរចេញពីលំនៅឋាន ឬទីសំណាក់បច្ចុប្បន្ន អាចត្រូវបានរឹតត្បិត ឬហាមឃាត់ លើកលែងតែក្នុងករណីចាំបាច់ ដូចខាងក្រោម៖

- ការធ្វើដំណើរទៅបំពេញការងារ ឬប្រកបមុខរបរ ឬអាជីវកម្ម ដែលមិនមានការរឹតត្បិត ឬហាមឃាត់ និងដោយមានភ្ជាប់លិខិតបញ្ជាក់អំពីការងារ មុខរបរ ឬអាជីវកម្ម
- ការធ្វើដំណើរទៅស្វែងរកគ្រឿងឧបភោគបរិភោគ និងសម្ភារៈប្រើប្រាស់ចាំបាច់ប្រចាំថ្ងៃ
- ការធ្វើដំណើរទៅមន្ទីរពេទ្យ មណ្ឌលសុខភាព សម្ភព ទីកន្លែងព្យាបាល ឬឱសថស្ថាន ដោយមូលហេតុសុខភាពបន្ទាន់
- ការធ្វើដំណើរដើម្បីទៅបង្ហាញខ្លួនឱ្យមន្ត្រីសុខាភិបាលធ្វើការយកវត្ថុសំណាកទៅវិភាគរកមេរោគកូវីដ-១៩ និងដើម្បីទទួលការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ តាមកាលកំណត់

- ការធ្វើសកម្មភាពកីឡាជាលក្ខណៈបុគ្គលក្នុងរង្វង់ភូមិសាស្ត្រឃុំ-សង្កាត់ដែលខ្លួនរស់នៅ ដោយចៀសវាងការជួបជុំប្រមូលផ្តុំមនុស្ស
- ការធ្វើដំណើរដើម្បីអនុវត្តកាតព្វកិច្ចតាមផ្លូវច្បាប់នៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ ឬសាលាជម្រះក្តី
- ការធ្វើដំណើរដើម្បីចូលរួមក្នុងសកម្មភាពដែលបម្រើផលប្រយោជន៍សាធារណៈ ឬគោលបំណងចាំបាច់ផ្សេងទៀត តាមការស្នើសុំ ឬតាមការកំណត់របស់អាជ្ញាធរសាធារណៈ និង
- ការធ្វើដំណើរដោយមូលហេតុចាំបាច់និងបន្ទាន់ក្នុងគ្រួសារ ជាអាទិ៍ ករណីមានសមាជិកគ្រួសារកំពុងមានជំងឺធ្ងន់ធ្ងរនិងត្រូវសង្គ្រោះបន្ទាន់ ឬករណីមានសមាជិកគ្រួសារទទួលមរណភាព។

**មាត្រា៥ .. ការរឹតត្បិត ឬការហាមឃាត់ការជួបជុំ ឬការប្រមូលផ្តុំមនុស្ស**

រាល់ការជួបជុំ ឬការប្រមូលផ្តុំមនុស្ស អាចត្រូវបានរឹតត្បិត ឬហាមឃាត់ លើកលែងតែក្នុងករណីចាំបាច់ ដូចខាងក្រោម៖

- ការជួបជុំក្នុងចំណោមសមាជិកគ្រួសារដែលរស់នៅក្នុងលំនៅឋានឬទីសំណាក់ជាមួយគ្នា
- ការរៀបចំពិធីបុណ្យសព ដោយគោរពតាមការកំណត់របស់អាជ្ញាធរមានសមត្ថកិច្ច
- ការប្រមូលផ្តុំមនុស្សដើម្បីអនុវត្តវិធានការសុខាភិបាល ជាអាទិ៍ ការយកវត្ថុសំណាកទៅវិភាគរកមេរោគកូវីដ-១៩ និងការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩
- ការជួបជុំមនុស្សដើម្បីផ្តល់ជំនួយចាំបាច់នានាដល់ជនងាយរងគ្រោះ ឬជនរងគ្រោះ
- ការជួបជុំមនុស្សក្នុងអំឡុងពេលនៃកិច្ចនីតិវិធីរបស់មន្ត្រីនគរបាលយុត្តិធម៌ ឬរបស់សាលាជម្រះក្តី និង
- ការជួបជុំមនុស្សដែលមានភាពចាំបាច់សម្រាប់បម្រើផលប្រយោជន៍សាធារណៈ ឬក្នុងគោលបំណងផ្សេងទៀតតាមការកំណត់របស់អាជ្ញាធរមានសមត្ថកិច្ច។

**មាត្រា៦ .. ការហាមឃាត់សកម្មភាពការងារ មុខរបរ ឬអាជីវកម្ម**

រាល់សកម្មភាពការងារ មុខរបរ ឬអាជីវកម្ម អាចត្រូវបានផ្អាកជាបណ្តោះអាសន្ន លើកលែងតែក្នុងករណីចាំបាច់ ដូចខាងក្រោម៖

- សកម្មភាពការងារនៅក្នុងក្របខណ្ឌមុខងារសាធារណៈ ឬការងារដែលពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈតាមការកំណត់របស់ស្ថាប័ននីមួយៗ ជាអាទិ៍ សេវាផ្គត់ផ្គង់អគ្គិសនី, ទឹក, សេវាប្រមូលសំរាម
- រាល់សកម្មភាពការងារ មុខរបរ ឬអាជីវកម្ម ដែលដំណើរការតាមរយៈប្រព័ន្ធអនឡាញ
- សេវាសង្គ្រោះបន្ទាន់ សេវាសុខាភិបាល និងឱសថស្ថាន
- ការផ្គត់ផ្គង់ទំនិញ ឬសេវាដែលជាតម្រូវការចាំបាច់ប្រចាំថ្ងៃ ជាអាទិ៍ ហាងលក់ទំនិញ, ស្ថានីយ៍ប្រេងឥន្ធនៈ, សេវាប្រៃសណីយ៍ និងទូរគមនាគមន៍
- ភោជនីយដ្ឋាន និងអាហារដ្ឋានដែលលក់អាហារវេចខ្ចប់
- សេវាកម្មដឹកជញ្ជូនទំនិញ និង
- សកម្មភាពការងារ មុខរបរ ឬអាជីវកម្មចាំបាច់ដទៃទៀត ដោយមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច។

**មាត្រា៧ .. ការរឹតត្បិត ឬហាមឃាត់ការធ្វើចរាចរណ៍ចេញ-ចូល**

ការធ្វើចរាចរណ៍ចេញ-ចូលភូមិសាស្ត្រនៃតំបន់ ឬទីកន្លែងណាមួយ ដែលមានការឆ្លងរាលដាលជំងឺ

កូវីដ-១៩ អាចត្រូវបានរឹតត្បិត ឬហាមឃាត់ លើកលែងតែសេវាសង្គ្រោះបន្ទាន់ សេវាសាធារណៈចាំបាច់និងបន្ទាន់ ឬសេវាដឹកជញ្ជូនទំនិញ។

### មាត្រា៨ .. បម្រាមគោចរ

រាល់ការធ្វើដំណើរដែលត្រូវបានអនុញ្ញាតដូចមានចែងក្នុងមាត្រា៤ នៃអនុក្រឹត្យនេះ មិនត្រូវធ្វើឡើងនៅចន្លោះពីម៉ោង ២០ (ម្ភៃ) ដល់ម៉ោង ៥ (ប្រាំ) លើកលែងចំពោះការធ្វើដំណើរដោយមូលហេតុសុខភាពបន្ទាន់ មូលហេតុចាំបាច់និងបន្ទាន់ក្នុងគ្រួសារ ការដឹកជញ្ជូនទំនិញ ការបំពេញកាតព្វកិច្ចដែលបម្រើផលប្រយោជន៍សាធារណៈ ការធ្វើដំណើរទៅទីកន្លែងបំពេញការងារនៅក្នុងសហគ្រាស គ្រឹះស្ថាន ឬទីតាំងអាជីវកម្មដែលត្រូវបានលើកលែងឱ្យបើកដំណើរការដូចមានចែងក្នុងកថាខណ្ឌខាងក្រោមនេះ និងករណីចាំបាច់ដទៃទៀតដោយមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច។

រាល់គ្រឹះស្ថានសាធារណៈ សហគ្រាសឬគ្រឹះស្ថានឯកជន ឬទីតាំងអាជីវកម្មដែលត្រូវបានអនុញ្ញាតឱ្យនៅបើកដំណើរការស្របតាមមាត្រា៦ នៃអនុក្រឹត្យនេះ ត្រូវផ្អាកប្រតិបត្តិការរបស់ខ្លួនចាប់ពីម៉ោង ២០ (ម្ភៃ) ដល់ម៉ោង ៥ (ប្រាំ) សម្រាប់ទទួលអតិថិជនដោយផ្ទាល់ លើកលែងចំពោះសេវាសង្គ្រោះបន្ទាន់ សេវាសុខាភិបាល ឱសថស្ថាន ស្ថានីយ៍ប្រេងឥន្ធនៈ និងសេវាសាធារណៈចាំបាច់ដទៃទៀតដោយមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច។

### មាត្រា៩ .. ការបិទខ្ទប់តំបន់ ឬទីកន្លែងដែលមានការឆ្លងរាលដាលនៃជំងឺកូវីដ-១៩

រាល់ការធ្វើដំណើរចេញ-ចូលភូមិសាស្ត្រនៃតំបន់ ឬទីកន្លែងដែលត្រូវបានបិទខ្ទប់ អាចត្រូវបានហាមឃាត់ លើកលែងតែការធ្វើដំណើរដើម្បីបំពេញមុខងារក្នុងការផ្តល់សេវាសង្គ្រោះបន្ទាន់ សេវាសាធារណៈចាំបាច់និងបន្ទាន់ ឬសេវាដឹកជញ្ជូនទំនិញ និងករណីចាំបាច់ផ្សេងទៀតដោយមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច។

ក្នុងអំឡុងពេលនៃការបិទខ្ទប់ វិធានការរដ្ឋបាលដែលមានចែងក្នុងមាត្រា៤ មាត្រា៥ មាត្រា៦ មាត្រា៧ មាត្រា៨ និងមាត្រា១០ នៃអនុក្រឹត្យនេះ ត្រូវបានយកមកអនុវត្តទាំងស្រុង ឬដោយផ្នែក។

ក្នុងអំឡុងពេលនៃការអនុវត្តវិធានការបិទខ្ទប់ បុគ្គលគ្រប់រូបមានកាតព្វកិច្ចត្រូវអនុវត្តវិធានការសុខាភិបាល រួមមានការពាក់ម៉ាស និងការរក្សាគម្លាតសុវត្ថិភាព ព្រមទាំងប្រកាន់ខ្ជាប់នូវការធ្វើអនាម័យដើម្បីសម្លាប់មេរោគ និងការវាស់កំដៅ ដើម្បីប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

### មាត្រា១០ .. ការរឹតត្បិត ឬការហាមឃាត់ការធ្វើពាណិជ្ជកម្មលើទំនិញដែលជាហានិភ័យ ឬជាប្រភពនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩

ទំនិញដែលជាហានិភ័យ ឬជាប្រភពនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ដែលកំណត់ដោយក្រសួងសុខាភិបាល អាចត្រូវបានរឹតត្បិត ឬហាមឃាត់ការធ្វើពាណិជ្ជកម្មតាមគ្រប់រូបភាពនៅលើទីផ្សារ និងការផ្គត់ផ្គង់នៅព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី៣
## សិទ្ធិអំណាចក្នុងការដាក់ចេញវិធានការរដ្ឋបាល

### មាត្រា១១ .. សមត្ថកិច្ចក្នុងការដាក់ចេញវិធានការរដ្ឋបាល

ការដាក់ចេញវិធានការបិទខ្ទប់រាជធានីឬខេត្ត និងការដាក់ចេញវិធានការរដ្ឋបាលផ្សេងទៀតដែលមានវិសាលភាពអនុវត្តលើសពីដែនដីនៃរាជធានី ឬខេត្តមួយ ឬមានវិសាលភាពអនុវត្តនៅទូទាំងប្រទេស ត្រូវធ្វើឡើងតាមសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

គណៈអភិបាលរាជធានី ខេត្ត ត្រូវបានប្រគល់សមត្ថកិច្ចក្នុងការសម្រេចដាក់ចេញវិធានការរដ្ឋបាលណាមួយដែលមានវិសាលភាពអនុវត្តសម្រាប់ផ្នែកខ្លះ ឬទីកន្លែងខ្លះក្នុងដែនដីនៃរាជធានីខេត្ត ឬមានវិសាលភាពអនុវត្តទូទាំងរាជធានី ឬខេត្តរបស់ខ្លួនដែលមានការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

**មាត្រា១២ .. លក្ខខណ្ឌនៃការដាក់ចេញវិធានការរដ្ឋបាល**

ការដាក់ចេញវិធានការរដ្ឋបាលណាមួយស្របតាមអនុក្រឹត្យនេះ ត្រូវធ្វើឡើងជាបណ្ដោះអាសន្នសម្រាប់ថិរវេលាមិនឱ្យលើសពី ២ (ពីរ) សប្ដាហ៍។ ថិរវេលានេះអាចត្រូវបានសម្រេចបន្ត ឬបញ្ចប់មុនថិរវេលាកំណត់ ក្នុងលក្ខខណ្ឌដូចគ្នានឹងការសម្រេចដាក់ចេញវិធានការរដ្ឋបាល ស្របតាមមាត្រា១១ នៃអនុក្រឹត្យនេះ។

**មាត្រា១៣ .- សិទ្ធិអំណាចរបស់គណៈអភិបាលរាជធានី ខេត្ត**

គណៈអភិបាលរាជធានី ខេត្តពាក់ព័ន្ធ ត្រូវបានប្រគល់ភារកិច្ចក្នុងការធានាការអនុវត្តវិធានការដែលត្រូវបានដាក់ចេញស្របតាមកថាខណ្ឌទី១ នៃមាត្រា១១ នៃអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព។

គណៈអភិបាលរាជធានី ខេត្តពាក់ព័ន្ធ មានសិទ្ធិបង្កើតយន្តការចាំបាច់នានា ដើម្បីតាមដាន ត្រួតពិនិត្យ និងអនុវត្តវិធានការដែលត្រូវបានដាក់ចេញស្របតាមមាត្រា១១ នៃអនុក្រឹត្យនេះ ក្រោមសមត្ថកិច្ចរបស់ខ្លួន។

គណៈអភិបាលរាជធានី ខេត្តពាក់ព័ន្ធ អាចចេញសេចក្ដីណែនាំលម្អិតអំពីការអនុវត្តវិធានការរដ្ឋបាលនានាដែលបានដាក់ចេញស្របតាមអនុក្រឹត្យនេះ ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្ត នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

គណៈអភិបាលរាជធានី ខេត្តពាក់ព័ន្ធ មានសិទ្ធិបន្ធូរបន្ថយនូវវិធានការរដ្ឋបាលណាមួយដែលត្រូវបានដាក់ចេញស្របតាមកថាខណ្ឌទី២ នៃមាត្រា១១ នៃអនុក្រឹត្យនេះ ប៉ុន្តែត្រូវគោរពឱ្យបាននូវរាល់លក្ខខណ្ឌលើកលែងដាក់លាក់នៃវិធានការរដ្ឋបាលនីមួយៗ ដូចបានកំណត់ក្នុងអនុក្រឹត្យនេះ។

ក្នុងករណីបន្ទាន់និងចាំបាច់ គណៈអភិបាលរាជធានី ខេត្តមានសិទ្ធិដាក់ចេញវិធានការរដ្ឋបាលផ្សេងទៀតសំដៅធានាដល់ប្រសិទ្ធភាពនៃការគ្រប់គ្រងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងដែនដីដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួន និងទប់ស្កាត់ជំងឺនេះមិនឱ្យឆ្លងរាលដាលទៅតំបន់ផ្សេងទៀត។

**ជំពូកទី៤**

**ទោសប្បញ្ញត្តិ**

**មាត្រា១៤ .. ទណ្ឌកម្មចំពោះអំពើមិនគោរពវិធានការរដ្ឋបាល**

ត្រូវផ្ដន្ទាទោសស្របតាមមាត្រា១០ នៃច្បាប់ស្ដីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ចំពោះបុគ្គលដែលមិនគោរពដោយចេតនានូវវិធានការរដ្ឋបាលដែលមានចែងក្នុងជំពូកទី២ និងជំពូកទី៣ នៃអនុក្រឹត្យនេះ។

ការសម្រេចដាក់ពិន័យអន្តរការណ៍ចំពោះការបំពានវិធានការរដ្ឋបាល ជាសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ បែបបទនីតិវិធីលម្អិតសម្រាប់ការដាក់ពិន័យអន្តរការណ៍ ត្រូវកំណត់ដោយគណៈអភិបាលរាជធានី ខេត្ត។

ទម្រង់បែបបទនៃបង្កាន់ដៃពិន័យ និងការគ្រប់គ្រងប្រាក់ដែលបានមកពីការពិន័យអន្តរការណ៍ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា១៥ .. ទណ្ឌកម្មចំពោះអំពើរារាំងដល់ការអនុវត្តវិធានការរដ្ឋបាល**

ត្រូវផ្ដន្ទាទោសស្របតាមមាត្រា១១ នៃច្បាប់ស្ដីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ចំពោះបុគ្គលដែលប្រព្រឹត្តអំពើរារាំងឬបង្កឧបសគ្គដោយចេតនាដល់ការអនុវត្តវិធានការរដ្ឋបាលដូចមានចែងក្នុងជំពូកទី២ និងជំពូកទី៣ នៃអនុក្រឹត្យនេះ។

**មាត្រា១៦ .. ទណ្ឌកម្មចំពោះអំពើមិនគោរពវិធានការសុខាភិបាល**

ត្រូវផ្តន្ទាទោសស្របតាមមាត្រា១៩ និងមាត្រា២០ នៃអនុក្រឹត្យស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ចំពោះបុគ្គលដែលមិនអនុវត្តកាតព្វកិច្ចដូចមានចែងក្នុងកថាខណ្ឌទី៣ នៃមាត្រា៩ នៃអនុក្រឹត្យនេះ។

**មាត្រា១៧ .. ការទទួលខុសត្រូវរបស់អាជ្ញាធរមានសមត្ថកិច្ច**

មន្ត្រីមានសមត្ថកិច្ចដែលប្រើប្រាស់សិទ្ធិអំណាចតាមទំនើងចិត្តដោយរំលោភបំពានខុសពីគោលបំណងនៃអនុក្រឹត្យនេះ បណ្តាលឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាព បូរណភាពរូបរាងកាយ ឬធ្វើឱ្យខូចខាតដល់ទ្រព្យសម្បត្តិរបស់បុគ្គលដទៃ ត្រូវទទួលខុសត្រូវចំពោះអំពើដែលខ្លួនបានប្រព្រឹត្តស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា១៨ .. ការលើកលែងឱ្យរួចផុតពីការទទួលខុសត្រូវ ឬទទួលបាននូវការសម្រាលការទទួលខុសត្រូវព្រហ្មទណ្ឌ**

ចំពោះបុគ្គលដែលបានប្រព្រឹត្តអំពើល្មើសដូចមានចែងក្នុងមាត្រា១៤ និងមាត្រា១៥ នៃអនុក្រឹត្យនេះ អាចត្រូវលើកលែងឱ្យរួចផុតពីការទទួលខុសត្រូវ ឬទទួលបាននូវការសម្រាលការទទួលខុសត្រូវព្រហ្មទណ្ឌ ប្រសិនបើបុគ្គលនោះបានបង្ហាញប្រាប់ព័ត៌មានដល់មន្ត្រីសុខាភិបាល ឬមន្ត្រីមានសមត្ថកិច្ច ឬបានផ្តល់កិច្ចសហការចាំបាច់នានាដើម្បីជាប្រយោជន៍ក្នុងការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ឱ្យបានទាន់ពេលវេលា។

ការលើកលែងឱ្យរួចផុតពីការទទួលខុសត្រូវ ឬទទួលបាននូវការសម្រាលការទទួលខុសត្រូវព្រហ្មទណ្ឌខាងលើ ក៏ត្រូវយកទៅអនុវត្តផងដែរ ក្នុងករណីដែលក្រុមគ្រួសារនៃបុគ្គលដែលបានប្រព្រឹត្តអំពើល្មើសដូចមានចែងក្នុងមាត្រា១៤ និងមាត្រា១៥ នៃអនុក្រឹត្យនេះ បានបង្ហាញប្រាប់ព័ត៌មានដល់មន្ត្រីសុខាភិបាល ឬមន្ត្រីមានសមត្ថកិច្ច ឬបានផ្តល់កិច្ចសហការចាំបាច់នានាដើម្បីជាប្រយោជន៍ក្នុងការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ឱ្យបានទាន់ពេលវេលា។

**មាត្រា១៩ .. ការអនុវត្តច្បាប់ព្រហ្មទណ្ឌផ្សេងទៀត**

ការអនុវត្តបទប្បញ្ញត្តិជំពូកទី៤ នៃអនុក្រឹត្យនេះ មិនរារាំងការអនុវត្តច្បាប់ព្រហ្មទណ្ឌផ្សេងទៀត ក្នុងករណីដែលអំពើបំពានលើបទប្បញ្ញត្តិដែលមានចែងក្នុងអនុក្រឹត្យនេះ ជាបទល្មើសដែលបានបញ្ញត្តក្នុងច្បាប់ព្រហ្មទណ្ឌផ្សេងទៀត។

## ជំពូកទី៥
## ការអនុវត្តដូចគ្នាចំពោះជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត

**មាត្រា២០ .. ការអនុវត្តដូចគ្នានូវបទប្បញ្ញត្តិដែលមានចែងក្នុងអនុក្រឹត្យនេះចំពោះជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត**

វិធានការរដ្ឋបាលទាំងឡាយ ព្រមទាំងទោសប្បញ្ញត្តិដែលមានចែងក្នុងអនុក្រឹត្យនេះ ដើម្បីអនុវត្តចំពោះជំងឺកូវីដ-១៩ ត្រូវមានអានុភាពអនុវត្តដូចគ្នាចំពោះជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត

ដែលត្រូវបានកំណត់ដោយក្រសួងសុខាភិបាល ក្រោមវិសាលភាពអនុវត្តនៃច្បាប់ស្ដីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត។

## ជំពូកទី៦
## អន្តរប្បញ្ញត្តិ

**មាត្រា២១ .. ការបន្តសុពលភាពនៃលិខិតបទដ្ឋានគតិយុត្តមុនអនុក្រឹត្យនេះ**

រាល់លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិធានការរដ្ឋបាលនានា ដើម្បីប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ដែលមានមុនពេលអនុក្រឹត្យនេះចូលជាធរមាន ហើយដែលមិនផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវមានអានុភាពអនុវត្តបន្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា២២ .. និរាករណ៍**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២៣ .. ស្ថាប័នអនុវត្ត**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ៣រោច ខែ ចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>**កន្លែងទទួល៖**</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ